# ២០-រឿង អាសំគមបាញ់លលក

មានបុរសម្នាក់ជាកូនត្រកូលកំសត់ទុគ៌ត បុរសនេះតាំងពីចម្រើនធំឡើងគ្មានរកស៊ីអ្វីសោះ ខំប្រឹងសង្វាតតែខាងការបរបាញ់ ទាល់តែស្ទាត់ជំនាញ បើបុរសនោះបាញ់តំរង់សត្វណាចង់អោយត្រូវក្បាល ត្រូវក ឬទ្រូងរមែងត្រូវតាមបំណង តែរូបឆោមលោមពណ៌បុរសនោះអាក្រក់មាឧស្គមកំព្រឹង សក់ក្រញាង មុខក្រញូះ អ្នកស្រុកគេដាក់ឈ្មោះហៅថា "អាសំគមបាញ់លលក" ព្រោះវាតែងដើរបាញ់លលករាល់ថ្ងៃ ។

ថ្ងៃមួយអាសំគមបាញ់លលក លីស្នាដើរទៅស្វែងរកបាញ់លលក បានប្រទះឃើញភូមិសេដ្ឋី១មានដើមឈើដុះ ត្រសាយត្រំសុំ ដង្គំដង្គោលជាទីលំនៅនៃបក្សីមានលលកជាដើម ។ សេដ្ឋីនោះជាអ្នកសម្បូណ៌សម្បុកសម្បត្តិ ព្រមទាំងមានកូនក្រមុំពីរនាក់ផង ។ អាសំគមបាញ់លលកលីស្នាដើរសៀរតាមរបងភូមិសេដ្ឋីក៏ជួនជាកូនស្រីសេដ្ឋីទាំងពីរបណ្តើរគ្នាលេង តាមសួនច្បារក្នុងភូមិរបស់ខ្លួន មីរដេរដាសដោយផ្កាវីកស្គុះស្គាយ ផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់នៅពេលព្រឹកព្រហាម ។ អាសំគមបាញ់លលកដើរសៀរតាមភូមិងើបមើលលើក្រែងមានសត្វលលកទំនៅចុងឈើ ។ កាលបើអាសំគមបាញ់លលកងាកភ្នែកចុះឡើងចោលកន្ទុយភ្នែកទៅក្នុងភូមិ ខ្សែភ្នែករត់ទៅប៉ះទង្គិចនឹងរូបរាងនាងក្រមុំទាំងពីរ ដែលប្រកបដោយគ្រឿងតែងប្រាណមានលំអស្រស់ស្រងៅទាំងមានព្រលឹងសាច់ទ្រលុកទ្រលន់ នាំអោយភ្ញាក់កន្ត្រាក់ដួងចិត្តប្រុស នៅវេលាឃើញដំបូង ។ ឯអាសំគមបាញ់លលក គ្រាន់តែភ្នែកទៅប៉ះរូបនាងនោះភ្លាម ក៏ស្រឡាំងកាំងភាំងស្មារតី ភ្លេចខ្លួនជ្រុះទាំងស្នាទាំងព្រួញដល់ដី ។ អាសំគមបាញ់លលក តាំងពីបានឃើញកូនសេដ្ឋីក៏ស្រឡាញ់ជាប់ក្នុងចិត្តនឹកឥតភ្លេច ហើយក៏ទៅផ្ទះថ្លែងប្រាប់ឪពុកម្តាយនិយាយនឹងម្តាយអោយទៅដណ្តឹងកូនសេដ្ឋីអោយ ។ ម្តាយនិយាយនឹងកូនថា "នែកូនម្តេចក៏ឯងទៅស្រឡាញ់កូនសេដ្ឋីអីចេះ បើឯងក្រីក្រភោគសម្បត្តិ ទាំងរូបឯងទៀត ក៏អាក្រក់មិនសមនឹងកូនគេធ្វើម្តេចគេនឹងអោយឯង" ។ អាសំគមបាញ់លលក ក៏និយាយ

និងម្តាយថា"ម៉ែ! បើម៉ែមិនទៅដណ្តឹងអោយខ្ញុំទេ ខ្ញុំក៏អស់ឃើញមុខម៉ែៗ ក៏លែងបានឃើញខ្ញុំពីថ្ងៃនេះទៅហើយ" ។

ម្តាយដែលមានចិត្តអាណិតកូន ឮកូននិយាយដូច្នោះ ក៏ស៊ូកាត់កេរ្តិ៍ខ្មាសទៅនិយាយស្នើការនឹងសេដ្ឋីៗ ក៏តបវិញថា"ខ្ញុំឥតបើស្អប់ខ្ពើមអីកូននាងទេប៉ុន្តែកូនខ្ញុំៗនឹងអោយពុំបាន ដ្បិតមិនទាន់គ្រប់ការ ណ្ហើយនាង! ប៉ុណ្ណោះទុកជាការស្រេចចុះកុំបាច់ទៅមកទៀត"សំដីប៉ុណ្ណោះជាសំដីបង្វែងដានមិនចង់អោយ ។ ម្តាយអាសំគមបាញ់លលកទញ់តុះគំនិត រកឧបាយនិយាយទៀតគ្មានក៏លាសេដ្ឋីត្រឡប់ទៅផ្ទះប្រាប់កូន ។ អាសំគមបាញ់លលក គ្រាន់តែម្តាយប្រាប់ដូច្នោះ ក៏ថ្លស់ទឹកមុខក្រៀមក្រំអង្គុយត្របោមក្បាលជង្គង់ ដង្ហើមឃ្សូរៗ បាយលែងនឹក ទឹកលែងស្រេកចេះតែនឹកមមៃៗហាក់ដូចជាកូនសេដ្ឋីនៅពីមុខស្រស់ៗ ដោយកម្លាំងសេចក្តីស្នេហាខ្លាំងពេក ហើយបែរជាមិនបានដូចបំណង ។ នៅវេលាដែលអាសំគមបាញ់លលកចូលដេក ក៏ចូលទៅទាំងនឹកអាល័យទៅជាមមើស្រែកច្រៀងទាំងយប់ថា"ឆោមអើយឆោមឆើតទាំងពីរប្រាណ ធ្វើម្តេចនឹងបានមកគៀកកើយអោយដូចជាពូក និង ខ្នល់ខ្នើយ បើម្លេះទៅហើយអស់សង្ឃឹម" ។

អាសំគមបាញ់លលក ទុកជាដឹងថាគេលែងអោយហើយដូច្នោះ លុះព្រឹកឡើងក៏នៅតែលីស្នា និង ស្ពាយបំពង់ព្រួញ ដើរសំដៅទៅភូមិសេដ្ឋីរាល់ថ្ងៃឥតខានសោះ ពួនចាំលបមើលកូនសេដ្ឋី ។

ថ្លែងពីបុរសម្នាក់ទៀត ជាកូនអ្នកមានសម្បត្តិ ទាំងរូបឆោមនោះក៏សក្តិសមទឹកមុខឡើងស្រស់បំព្រងជាទីពេញចំណង់នៃស្ត្រីភាព ។ បុរសនោះ ក៏ស្រឡាញ់កូនសេដ្ឋីនោះដែរ លុះទៅដណ្តឹងសេដ្ឋីក៏មិនព្រមអោយ ។ បុរសនោះទុកជាដឹងថាគេមិនព្រមអោយក៏នៅតែទៅលបមើលកូនសេដ្ឋីរាល់ថ្ងៃ ។ ជួនជាពេលមួយបុរសនោះក៏ទៅអាសំគមបាញ់លលកក៏មកជួបគ្នា អាសំគមបាញ់លលកសួរថា"អ្នកឯងទៅណា?"បុរសនោះឆ្លើយថា"ខ្ញុំមកលបមើលកូនសេដ្ឋី"ឆ្លើយហើយសួរថា"ចុះឯងមកធ្វើអ្វីដែរ?" ។ អាសំគមបាញ់លលកថា"ខ្ញុំក៏មកមើលកូនសេដ្ឋីដែរ" ។ បុរសនោះថា"យើ! រាងនេះអួតឯងចង់បានកូនសេដ្ឋីផង ប៉ុនអម្បាលរូបខ្ញុំ គេនៅតែមិនអោយ" ។ អាសំគមបាញ់លលកថា"បងឯងចាំមើលខ្ញុំយកអោយទាល់តែបាន" ។

ថ្ងៃមួយសេដ្ឋីប្តីប្រពន្ធ នាំគ្នាទៅវត្តនៅតែកូនក្រមុំពីរនាក់ចាំផ្ទះ ។ អាសំគមបាញ់លលកដឹងដូច្នោះ ក៏រកឧបាយគ្រានោះជួនជាមានសត្វលលកមួយទំនៅចុងឈើមុខផ្ទះសេដ្ឋី ។ អាសំគមបាញ់លលកបានឱកាស ក៏យឹតស្នាបាញ់ឮសូរក្លឹងប៉ាប់ស្រាប់តែលលកធ្លាក់ជើងទទះស្លាប នៅទីធ្លាមុខផ្ទះ ។ លំដាប់នោះកូនក្រមុំសេដ្ឋីម្នាក់ចុះទៅដីឃើញលលកនោះហើយ ក៏ស្រែកប្រាប់បងថា"អ្នកបង! អ្នកណាបាញ់លលកធ្លាក់មកនេះ?" ថាហើយក៏រើសលលកទៅ ។ អាសំគមបាញ់លលកធ្វើដូចជាមិនដឹង ដល់គេបោចរួចហើយ ស្រាប់តែឡូឡារកលលកដែលខ្លួនបាញ់នោះថា"នរណាលួចលលកអញទៅណា ? តែអញរកឃើញ មុខជាប្តឹងរាជការអោយយកទៅដាក់គុកពុំខាន" ។ នាងក្រមុំទាំងពីរនាក់ឮដូច្នោះ ក៏ភ័យស្រែកប្រាប់ថា"លលកបងឯងខ្ញុំយកមកនេះហើយ" ។ អាសំគមបាញ់លលកស្តីគម្រាមអោយថា "ម៉េចក៏ហ៊ានលួចលលកអញ ត្រូវយកមកអោយអញ" ។ កូនសេដ្ឋីក៏យកលលកមកអោយ ។ អាសំគមបាញ់លលកថា "ទេ! លលកអញនៅរោមនៅស្លាប ឥឡូវនាងឯងយកទៅបោចរោមស្លាបអស់ហើយ ក្រែងតែអាំងឆ្អិនអោយអញបានអញយក" ។ នាងក្រមុំទាំងពីរក៏យកទៅអាំងឆ្អិន ហើយយកមកអោយ ។ អាសំគមបាញ់លលកថា នរណាស៊ីតែសាច់លលកក្រែងតែមានស្រាផឹកផងបានសុខកើត"នាងទាំងពីរនាក់ ហេតុតែខ្លួនជាស្រីប្រកបដោយសេចក្តីភិតភ័យច្រើន ក៏ទៅយកស្រាមកអោយ អោយមួយពែងហើយ ថាមួយពែងទៀត ទាល់តែស្រវឹងដួលដេកលើផ្ទះនោះទៅ ។ ឯនាងក្រមុំទាំងពីរនាក់គិតថា "បើយើងបណ្តោយអោយវានៅហ្នឹងតែឪម៉ែមកវិញឃើញ យើងមុខជាមានរឿង គិតហើយមិនដឹងយកទៅណា ក៏នាំគ្នាសែងអាសំគមបាញ់លលកទៅលាក់ទុកក្នុងផ្ទះ ។ ដល់ពេលយប់អាសំគមបាញ់លលកដឹងខ្លួន ស្រាប់តែស្រែកថា "មួសខាំណាស់" ។ កូនសេដ្ឋីនឹកភ័យក្រែងឪពុកដឹងក៏នាំសែងទៅដាក់ក្រោមគ្រែដេករបស់ខ្លួន ។ អាសំគមបាញ់លលកស្រែកទៀត

ថា"សង្អើចខាំណាស់" ។ នាងទាំងពីរនាក់ ក៏លើកមកអោយដេកលើគ្រែក្នុងមុងជាមួយ ដោយគិតថាវាស្រវឹងស្រា នឹងធ្វើអ្វី ។ ពេលនោះអាសំគមបាញ់លលកបានឱកាស ក៏តាំងលូកប្រឡែងស្ទាបអង្អែលដោយសេចក្ដីស្រឡាញ់ដរាបដល់បានរួមដំណេកជាមួយនឹងនាងក្រមុំទាំងពីរនាក់នោះទៅ ។

## ចេះដប់មិនស្មើប្រសប់មួយ